**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៥៣៧/១០ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី២៣.ខែកញ្ញា.ឆ្នាំ២០១០.

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**ជម្រាបមក**

**លោក វ៉ន ចាវ៉ែន តំណាងសហគមន៍ជនជាតិដើមភាគតិច គ្រឹង**

**ភូមិកាំ ឃុំល្អក់ ស្រុកអូរជុំ**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិកាំ ឃុំល្អក់ ស្រុកអូរជុំ

**យោង:** - លិខិតចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ ២០១០ ស្តីពីការស្នើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិកាំ របស់លោក វ៉ន ចាវ៉ែន តំណាងសហគមន៍។

- លិខិតលេខ២៤៩/១០ ល.អ.ខ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ២០១០ ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិកាំ របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។

- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិកាំ របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទយល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិកាំ ឃុំល្អក់ ស្រុកអូរជុំ ខេត្តរតនគិរីតាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច គ្រឹង ភូមិកាំ អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញា និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវសេចក្តីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ជា សុផារ៉ា

_ចម្លងជូន_

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-ក្រសួងទេសចរណ៍

"ដើម្បីជូនជ្រាប"

-សាលាខេត្តរតនគិរី

-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី

"ដើម្បីមុខការ"

-ឯកសារកាលប្បវត្តិ